# ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២២០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.- បង្កើតគ្រឹះស្ថានសាធារណៈមួយ ដែលមានឧបនិស្ស័យវប្បធម៌ និងវិទ្យាសាស្ត្រ មានឈ្មោះថា **"រាជបណ្ឌិតសភាកម្ពុជា"** ដែលមានឋានៈស្មើរដ្ឋលេខាធិការដ្ឋាន ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

មាត្រា ២.- រាជបណ្ឌិតសភាកម្ពុជា គឺជាគ្រឹះស្ថានសាធារណៈ មាននីតិបុគ្គលភាព និងមានស្វ័យភាព ខាងការគ្រប់គ្រង និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៣.- រាជបណ្ឌិតសភាកម្ពុជា មានបេសកកម្មលើកទឹកចិត្ត ណែនាំ គ្រប់គ្រង និងពង្រីកការស្រាវជ្រាវ មុខជំនាញនៅក្នុងប្រទេសនិងស្ថាប័នទាក់ទងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយ អង្គការជាតិ និងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា ។

## ជំពូកទី ២

## សមាជិកបណ្ឌិតសភា និង សមាជិកឆ្លើយឆ្លង

មាត្រា ៤.- រាជបណ្ឌិតសភាកម្ពុជា មានសមាជិកបណ្ឌិតសភា ៣ប្រភេទ :

១) **សមាជិកពេញសិទ្ធិ** (Membre titulaire) ត្រូវជ្រើសរើសដោយការបោះឆ្នោតសំងាត់ ក្នុងចំណោមសមាជិកបំរុង នៃរាជបណ្ឌិតសភាកម្ពុជា ដែលកំពុងបំពេញភារកិច្ច ។ សមាជិកពេញសិទ្ធិអាចមានចំនួនពី ៤០ ទៅ ៧០នាក់ ។

សំរាប់អាណត្តិ ០៥ឆ្នាំដំបូង សមាជិកពេញសិទ្ធិចំនួន ៩០នាក់ នឹងត្រូវតែងតាំងដោយអនុក្រឹត្យពីនាយករដ្ឋមន្ត្រី ។

២) សមាជិកបំរុង ( Membre postulant ) ត្រូវជ្រើសរើសដោយការបោះឆ្នោតសំងាត់របស់សមាជិកពេញសិទ្ធិ ពីក្នុងចំណោមអ្នកមានសញ្ញាប័ត្របណ្ឌិត ដែលបានដាក់ពាក្យសុំចូល ។

៣) សមាជិកសមាគមិក ( Membre associé ) ត្រូវជ្រើសរើសដោយការបោះឆ្នោតសំងាត់របស់សមាជិកពេញសិទ្ធិ ពីក្នុងចំណោមជនបរទេសដែលរស់នៅក្នុង ឬក្រៅប្រទេសកម្ពុជា ហើយដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវប្បធម៌ និងវិទ្យាសាស្ត្រជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ។

មាត្រា ៥.- រាជបណ្ឌិតសភាកម្ពុជា មានសមាជិកឆ្លើយឆ្លង ២ប្រភេទ ៖

១) សមាជិកឆ្លើយឆ្លងជាតិ ជាជនជាតិខ្មែររស់នៅក្នុង និងក្រៅប្រទេស ដែលស្ម័គ្រចិត្តរក្សាទំនាក់ទំនងជានិច្ចកាលជាមួយរាជបណ្ឌិតសភាកម្ពុជា ។

២) សមាជិកឆ្លើយឆ្លងអន្តរជាតិ ជាបណ្ឌិតជនមានសញ្ជាតិបរទេស រស់នៅក្នុង និងក្រៅប្រទេសកម្ពុជា ដែលស្ម័គ្រចិត្តរក្សាទំនាក់ទំនងជានិច្ចកាល ជាមួយរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៦.- លក្ខណៈជាសមាជិកពេញសិទ្ធិ ជាសមាជិកបំរុង ឬជាសមាជិកឆ្លើយឆ្លង ត្រូវរំលាយបាត់ទៅវិញដោយមរណភាព ឬដោយការសុំលាឈប់ ។

## ជំពូកទី ៣

## អង្គការដឹកនាំ

## ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

### ១-ក្រុមប្រឹក្សាភិបាល ៖

មាត្រា ៧.- រាជបណ្ឌិតសភាកម្ពុជា ស្ថិតនៅក្រោមការដឹកនាំនៃក្រុមប្រឹក្សាភិបាលមួយ ដែលមាននាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស និងមានសមាសភាព ដូចខាងក្រោមនេះ ៖

- ប្រធានរាជបណ្ឌិតសភាកម្ពុជា ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
- តំណាងវិទ្យាស្ថានភាសាជាតិ អនុប្រធាន
- សមាជិកគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យនានា សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា សមាជិកកត់ត្រា

ក្រុមប្រឹក្សាភិបាលមានអាណត្តិទៅតាមមុខតំណែងសាមីជនរៀងៗខ្លួន ។

**មាត្រា ៨.-** ក្រុមប្រឹក្សាភិបាលប្រជុំប្រចាំចតុមាស លើកលែងតែមានករណីចាំបាច់ ដែលត្រូវប្រជុំវិសាមញ្ញ ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកកោះប្រជុំក្រុមប្រឹក្សាភិបាល ។ សម័យប្រជុំអាចប្រព្រឹត្តទៅបានការលុះត្រាតែមានសមាជិកចំនួនភាគច្រើនដាច់ខាត (៥០% + ១) ដោយមានប្រធាន ឬអនុប្រធានចូលរួម។ សេចក្តីសម្រេចចិត្តត្រូវយកតាមសំឡេងភាគច្រើន បើមានសំឡេងស្មើគ្នា សំលេងប្រធានជាសំលេងកំណត់ ។ សមាជិកទាំងអស់ដែលបានមកប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំ ។

**មាត្រា ៩.-** ក្រុមប្រឹក្សាភិបាលមានភារកិច្ច ៖

១) អនុម័តលើបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈនៃបុគ្គលិករាជបណ្ឌិតសភាកម្ពុជា

២) សំរេចចិត្តបង្កើតមន្ទីរពិសោធន៍ កន្លែងអនុវត្តការពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវផ្សេងៗ ដើម្បីឲ្យរាជបណ្ឌិតសភាកម្ពុជាអនុវត្តការងារបានសមស្រប

៣) កំណត់ការបែងចែកចំនួនកន្លែងបុគ្គលិកក្នុងវិទ្យាស្ថានផ្សេងៗ និងសំរេចលើការជ្រើសរើសសមាជិកនៃរាជបណ្ឌិតសភាកម្ពុជា

៤) អនុម័តលើគំរោងថវិកា នៃរាជបណ្ឌិតសភាកម្ពុជា និងកម្មវិធីប្រចាំឆ្នាំ ឬផែនការរយៈពេលវែងរបស់រាជបណ្ឌិតសភាកម្ពុជា

៥) អនុម័តលើតុល្យការ និងលើតុល្យការនៅចុងការិយបរិច្ឆេទ

៦) អនុម័តលើកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗ

៧) ទទួលអំណោយ និងប្រាក់ឧបត្ថម្ភផ្សេងៗ

៨) បង្កើត និងផ្តល់រង្វាន់ដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលបានបង្កើតសមិទ្ធិស្របនឹងគោលបំណងរបស់រាជបណ្ឌិតសភាកម្ពុជា

៩) ត្រួតពិនិត្យរបាយការណ៍របស់គណៈកម្មាធិការប្រតិបត្តិ ។

១០) ត្រួតពិនិត្យការគ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ ។

**ខ- គណៈកម្មាធិការប្រតិបត្តិ**

**មាត្រា ១០.-** រាជបណ្ឌិតសភាកម្ពុជាត្រូវគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិមួយ ដែលរួមមាន បណ្ឌិត ០៥នាក់ គឺ ៖

- ប្រធាន
- សមាជិក ០១នាក់ : ទទួលបន្ទុក ០២វិទ្យាស្ថាន

- សមាជិក ០១នាក់ ៈ ទទួលបន្ទុក ០៦វិទ្យាស្ថាន
- សមាជិក ០១នាក់ ៈ ទទួលបន្ទុកជាអគ្គលេខាធិការ

ដោយឡែក វិទ្យាស្ថានភាសាជាតិស្ថិតនៅក្រោមការទទួលបន្ទុករបស់សមាជិកណាម្នាក់នៃក្រុមប្រឹក្សាភិបាល ។

**មាត្រា ១១.-** ប្រធានគណៈកម្មាធិការប្រតិបត្តិ មានឋានៈស្មើរដ្ឋលេខាធិការ សមាជិកទាំង ០៧រូប មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ១២.-** ប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវជ្រើសរើសដោយសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា តាមរយៈការបោះឆ្នោតសំងាត់ សំរាប់អាណត្តិ ០៥ឆ្នាំ ។ ក្នុងអាណត្តិ ០៥ឆ្នាំដំបូងនេះ ក្រៅពីប្រធាន សមាជិកទាំង០៧រូបត្រូវជ្រើសរើសពីក្នុងចំណោមសមាជិកពេញសិទ្ធិ និងដោយសមាជិកពេញសិទ្ធិ តាមរយៈការបោះឆ្នោតសំងាត់ ។

**មាត្រា ១៣.-** ប្រធានរាជបណ្ឌិតសភាកម្ពុជាដឹកនាំការប្រជុំ គណៈកម្មាធិការប្រតិបត្តិ ដោយរក្សារបៀបរៀបរយនៃការប្រជុំ និងអាចអញ្ជើញឥស្សរជនពីខាងក្រៅមកចូលរួម ។ ការប្រជុំនេះ ត្រូវមានការចូលរួមពីអគ្គនាយក ឬអគ្គនាយករង និងពីប្រធាន ឬអនុប្រធានវិទ្យាស្ថាន ។

**មាត្រា ១៤.-** ក្នុងករណីដែលប្រធានមានធុរកិច្ច សមាជិកមួយរូបនៃគណៈកម្មាធិការប្រតិបត្តិនឹងត្រូវចាត់តាំងដោយប្រធានឲ្យដឹកនាំការប្រជុំជំនួស ។

## ជំពូកទី ៤

## មហាសន្និបាត

**មាត្រា ១៥.-** មហាសន្និបាតត្រូវធ្វើតែក្នុងក្របខ័ណ្ឌសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា ។ សមាជិកផ្សេងៗទៀត អាចចូលស្តាប់ និងពិភាក្សា ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត ។

**មាត្រា ១៦.-** មហាសន្និបាតសាមញ្ញប្រចាំឆ្នាំ ត្រូវរៀបចំធ្វើនៅខែ មករា រៀងរាល់ឆ្នាំ ដើម្បីៈ

១-ស្តាប់របាយការណ៍របស់ប្រធាន ស្តីពីសកម្មភាពនៃរាជបណ្ឌិតសភាកម្ពុជា

២-ស្តាប់របាយកាណ៍របស់ស្នងការគណនី ស្តីពីស្ថានភាពហិរញ្ញវត្ថុ នៃរាជបណ្ឌិតសភាកម្ពុជា

៣-ពិភាក្សាលើបញ្ហាដែលមានចែងក្នុងរបៀបវារៈ ។

**មាត្រា ១៧.-** មហាសន្និបាតវិសាមញ្ញ ត្រូវកោះប្រជុំ ០៥ឆ្នាំម្តង ដើម្បីជ្រើសរើសប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ សំរាប់អាណត្តិថ្មី , ក្នុងករណីដែលមហាសន្និបាតសាមញ្ញ និងវិសាមញ្ញជាន់ឆ្នាំគ្នា មហាសន្និបាតត្រូវប្រព្រឹត្តទៅតែមួយលើក ដោយបញ្ចូលរបៀបវារៈរួមគ្នា ។

**មាត្រា ១៨.-** មហាសន្និបាតនឹងយកជាបានការ លុះត្រាតែមានសមាជិកពេញសិទ្ធិយ៉ាងតិចត្រឹមពាក់កណ្ដាលមកប្រជុំ ។ សេចក្ដីសំរេចត្រូវយកតាមសំលេងភាគច្រើន ។ បើមានសំលេងស្មើគ្នា សំលេងរបស់ប្រធានទុកជាបានការ ។

**មាត្រា ១៩.-** បើមហាសន្និបាតមិនគ្រប់កូរ៉ុម មហាសន្និបាតថ្មីមួយទៀត ត្រូវកោះប្រជុំ ១៥ថ្ងៃ ក្រោយពីថ្ងៃប្រជុំមហាសន្និបាតមុន ។ មហាសន្និបាតទី ២ នេះ អាចយកជាបានការ លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិចចំនួន មួយភាគបី ។

## ជំពូកទី ៥

## ស្ថាប័នឧបសម្ព័ន្ធ នៃរាជបណ្ឌិតសភាកម្ពុជា

**មាត្រា ២០.-** រាជបណ្ឌិតសភាកម្ពុជា មានវិទ្យាស្ថានឧបសម្ព័ន្ធចំនួន ០៥ ដូចខាងក្រោមនេះ ៖

១- វិទ្យាស្ថាន វប្បធម៌ និង វិចិត្រសិល្បៈ

ក- ផ្នែកវប្បធម៌ និងអរិយធម៌

ខ- ផ្នែកសិល្បៈសូនរូប និងឥស្សរិយយស

គ- ផ្នែកស្ថាបត្យកម្ម

ឃ- ផ្នែកបូរាណវិទ្យា

ង- ផ្នែកសិល្បៈប្រជាប្រិយ

២- វិទ្យាស្ថាន មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម

ក- ផ្នែកធម្មសាស្ត្រ និងចរិយាសាស្ត្រ

ខ- ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

គ- ផ្នែកពាណិជ្ជសាស្ត្រ និង ការគ្រប់គ្រង

ឃ- ផ្នែកប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ

ង- ផ្នែកភូមិវិទ្យា និងនគរូបនីយកម្ម

ច- ផ្នែកទស្សនវិជ្ជា និងសង្គមវិជ្ជា

ឆ- ផ្នែកនរវិទ្យា និងជាតិពន្ធុវិទ្យា

ជ- ផ្នែកចិត្តវិទ្យា និងវិទ្យាសាស្ត្រអប់រំ

៣- វិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម

ក- ផ្នែកបរិស្ថានធម្មជាតិ និងជីវវិទ្យា

ខ- ផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ

គ- ផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឃ-ផ្នែកធនធានទឹក

៤- វិទ្យាស្ថាន វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

ក- ផ្នែកគណិតវិទ្យា និងស្ថិតិ

ខ- ផ្នែកគីមី និង ចំណីអាហារ

គ- ផ្នែករូបវិទ្យា និងថាមពល

ឃ-ផ្នែកបច្ចេកវិទ្យា

ង- ផ្នែកពត៌មានវិទ្យា និង ទូរគមនាគមន៍

៥- វិទ្យាស្ថាន ភាសាជាតិ

ក- ផ្នែកវេយ្យាករណ៍ វចនានុក្រម និងបកប្រែ

ខ- ផ្នែកភាសា និងភាសាវិទ្យា

គ- ផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍

ឃ-ផ្នែកសិលាចារឹកវិទ្យា

មាត្រា ២១.- វិទ្យាស្ថាននីមួយៗ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីចាត់ការមួយ ដែលមាន ៖

- ប្រធានវិទ្យាស្ថាន ០១នាក់
- អនុប្រធានវិទ្យាស្ថាន ០១នាក់ ឬច្រើននាក់តាមការចាំបាច់
- លេខាធិការដ្ឋាន ០១ ដែលមានបុគ្គលិកមួយចំនួន

មាត្រា ២២.- ផ្នែកនីមួយៗ ត្រូវគ្រប់គ្រងដោយប្រធានផ្នែក ០១នាក់ និងអនុប្រធាន ០១នាក់ ឬច្រើននាក់តាមការចាំបាច់ ទៅតាមការតែងតាំងរបស់ប្រធានវិទ្យាស្ថាន ។

## ជំពូកទី ៦

## អគ្គការហិរញ្ញវត្ថុ

មាត្រា ២៣.- កាលបរិច្ឆេទហិរញ្ញវត្ថុ នៃរាជបណ្ឌិតសភាកម្ពុជា គឺពីថ្ងៃទី ០១ មករា ទៅទល់នឹងថ្ងៃទី ៣១ ធ្នូ ។ ក្រុមប្រឹក្សាភិបាលពិនិត្យ សំរេចលើគំរោងថវិកាក្នុងរវាង ២ខែ មុនចាប់ផ្តើម ។ ថវិកាត្រូវគ្រោងទុកនូវប្រាក់ចំណូល និងប្រាក់ចំណាយ សំរាប់ចាត់ចែងក្នុងរាជបណ្ឌិតសភាកម្ពុជា និងក្នុងការធានានូវដំណើរប្រព្រឹត្តទៅនៃផ្នែកនានានៅក្រោមឱវាទ ។

មាត្រា ២៤.- ប្រាក់ចំណូល នៃរាជបណ្ឌិតសភាកម្ពុជាមាន ៖

- ប្រភពពីថវិកាជាតិ

- ប្រាក់ចំណូលបានមកពីការលក់ស្នាដៃបោះពុម្ពផ្សាយ កិច្ចការស្រាវជ្រាវ និងសេវាផ្សេងៗ
- អំណោយ និងមរតកពីសប្បុរសជន និងជំនួយឧបត្ថម្ភពីអង្គការជាតិ និងអន្តរជាតិ

មាត្រា ២៥.- អគ្គលេខាធិការ ដែលបំពេញមុខងារជាអ្នកចាត់ចែងប្រាក់ចំណាយ ត្រូវធ្វើការបញ្ជាក់លើលិខិតចំណូល-ចំណាយ ហើយត្រូវទទួលខុសត្រូវក្នុងការរក្សាប្រាក់ និងរបៀបបញ្ជាន់បញ្ជី ។

## ជំពូកទី ៧

## ការត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២៦.- ការត្រួតពិនិត្យហិរញ្ញវត្ថុលើរាជបណ្ឌិតសភាកម្ពុជា ត្រូវធ្វើដោយស្នងការគណនី ០២នាក់ មួយនាក់ត្រូវតែងតាំងដោយនាយករដ្ឋមន្ត្រី និងមួយនាក់ទៀតត្រូវតែងតាំងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ស្នងការគណនីត្រូវបានទទួលប្រាក់បំណាច់ តាមការកំណត់ពីក្រុមប្រឹក្សាភិបាល ។

មាត្រា ២៧.- ស្នងការគណនី ត្រូវបញ្ជូនជារៀងរាល់ឆ្នាំនូវរបាយការណ៍ទៅនាយករដ្ឋមន្ត្រី និងទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីលទ្ធផលនៃការត្រួតពិនិត្យរបស់ខ្លួន ។

## ជំពូកទី ៨

## អន្តរបញ្ញត្តិ

មាត្រា ២៨.- ក្នុងពេលដំណើរការដំបូង រាជបណ្ឌិតសភាកម្ពុជា ត្រូវស្ថិតនៅក្រោមការដឹកនាំជាបណ្ដោះអាសន្នពីនាយករដ្ឋមន្ត្រី ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

មាត្រា ២៩.- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣០.- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣១.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ